# ជម្ងឺតម្រងនោមដែលកើតឡើងដោយសារជម្ងឺទឹកនោមផ្អែម
(Kidney Disease of Diabetes)

នៅសហរដ្ឋអាមេរិក ក្នុងមួយឆ្នាំៗ មានមនុស្សចំនួនជិតទៅ 10 (100,000) ម៉ឺននាក់ ដែលមានជម្ងឺខូចតម្រងនោម, ជម្ងឺម្យ៉ាងដែលធ្វើឲ្យតម្រងនោមពុំអាចមានលទ្ធភាពនឹងត្រងចម្រាញ់ជាតិសំណល់ពីរាងកាយបាន។ លក្ខណៈនេះ គឺជាដំណាក់ការចុងក្រោយបង្អស់នៃជម្ងឺតម្រងនោមដែលខូចខាត ម្តងបន្តិចៗ អស់រយៈពេលជាយូរមកហើយ (Nephropathy) ។ មនុស្សយើងមានតម្រងនោមពីរ ដែលស្ថិតនៅចំចង្កេះ។ អ្នកខ្លះហៅតម្រងនោមថា ក្រលៀន ដូចជា "ក្រលៀនជ្រូក" ឬ "ក្រលៀនគោ"។ អ្នកខ្លះខូចតម្រងនោមមួយ តែគាត់អាចនៅរស់បានដែរ។

យោលទៅតាមស្ថិតិមួយបានឲ្យដឹងថា ចំនួន 40% នៃជម្ងឺខូចតម្រងនោម គឺបណ្តាលមកពីជម្ងឺទឹកនោមផ្អែម។ ទោះបីជាមានថ្នាំនិងវិធីទទួលទានអាហារអាចជួយទប់ទល់ជម្ងឺទឹកនោមផ្អែមយ៉ាងណាក៏ដោយ ក៏ជម្ងឺនេះនៅតែអាចបណ្តាលឲ្យមានជម្ងឺតម្រងនោមបានដែរ។ អ្នកដែលកើតជម្ងឺទឹកនោមផ្អែមភាគច្រើន ពុំអាចកើតជម្ងឺតម្រងនោមដែលមានលក្ខណៈ ធ្ងន់ធ្ងររហូតដល់ខូចតម្រងនោមបាននោះឡើយ។ នៅក្នុងសហរដ្ឋមានមនុស្សចំនួនប្រហែល 17 លាន នាក់ ដែលកើតជម្ងឺទឹកនោមផ្អែម ហើយមានចំនួនជាង 10 ម៉ឺន នាក់ត្រូវខូចតម្រងនោមដោយសារជម្ងឺទឹកនោមផ្អែមនេះ។ នៅក្នុងឆ្នាំ 2000 មនុស្សដែលកើតជម្ងឺខូចតម្រងនោមមានចំនួនច្រើនជាងមនុស្ស ដែលឈឺជម្ងឺដទៃទៀត គឺមានចំនួន 10ម៉ឺននាក់ (ជាជម្ងឺទីពីរ) បន្ទាប់ពីជម្ងឺមហារីកសួត ដែលមានចំនួន 16 ម៉ឺននាក់។ ប្រសិនបើប្រៀបធៀបទៅនឹងជនជាតិស្បែកស ជនជាតិអាស៊ីអាចមានជម្ងឺខូចតម្រងនោមចំនួន 1.3% ច្រើនជាងជនជាតិស្បែកស។

ជម្ងឺទឹកនោមផ្អែមជាជម្ងឺដែលធ្វើឲ្យរាងកាយយើងពុំមានលទ្ធភាពធ្វើការនិងរំលាយអាហារឲ្យបានប្រក្រតី។ ជាធម្មតា រាងកាយត្រូវរំលាយអាហារហើយបញ្ចេញជាជាតិស្ករហៅថា Glucose ដែលជា ជាតិបង្កើតកម្លាំងថាមពលដល់រាងកាយ។ ដើម្បីឲ្យជាតិស្ករជ្រាបចូលក្នុងរាងកាយ ជាតិស្ករទាំងនេះ ត្រូវការជាតិអ៊ិនសូលិនពីលំពែង។ មនុស្សយើងកើតជម្ងឺទឹកនោមផ្អែម នៅពេលណាដែលលំពែងពុំអាចបញ្ចេញជាតិអ៊ិនសូលិនឲ្យបានគ្រប់គ្រាន់ សំរាប់ធ្វើឲ្យជាតិស្ករជ្រាបក្នុងរាងកាយ។ កត្តានេះ បណ្តាលឲ្យជាតិស្ករស្ថិតនៅតែក្នុងសរសៃឈាម ហើយការមានជាតិស្ករច្រើននៅក្នុងសរសៃឈាមនេះឯង ដែលបណ្តាលឲ្យមនុស្សកើតជម្ងឺទឹកនោមផ្អែម។

អ្នកជម្ងឺខូចតម្រងនោមត្រូវទទួលការព្យាបាលដោយការលាងឈាម (Hemodialysis) ឬដោយការប្តូរតម្រងនោមថ្មី (Kidney Transplantation)។ នៅឆ្នាំ 2000 រដ្ឋាភិបាលសហរដ្ឋអាមេរិក

ត្រូវចំណាយថវិការចំនួន 20 billion (2 ពាន់កោដិ) សំរាប់ព្យាបាលអ្នកជម្ងឺខូចតម្រងនោម។ អ្នកស្រាវជ្រាវបានរកឃើញថា ការមានសម្ពាធឈាមខ្ពស់ (លើសឈាម) និងការមានជាតិស្ករក្នុងឈាមច្រើន ជាកត្តាមួយ ដែលអាចបណ្តាលឲ្យអ្នកកើតជម្ងឺទឹកនោមផ្អែមខូចតម្រងនោម។

តម្រងនោមខូចដោយសារជម្ងឺទឹកនោមផ្អែមអាចមានរយៈពេលច្រើនឆ្នាំ។ បន្ទាប់មក វាអាចធ្វើអ្នកជម្ងឺកើតជម្ងឺលើសឈាមថែមទៀត។ ជាទូទៅ ការខូចតម្រងនោម អាចចាប់ផ្តើមធ្វើទុក្ខបន្ទាប់ពីពេលមនុស្សមានជម្ងឺទឹកនោមផ្អែមបានពី 15 ឆ្នាំ ទៅ 25 ឆ្នាំ។ បន្ទាប់ពីរយៈពេល 25 ឆ្នាំទៅ ការអាចកើតជម្ងឺខូចតម្រងនោមច្រើនចុះថយទៅវិញ។

នៅពេលអ្នកជម្ងឺទឹកផ្អែមចាប់ផ្តើមខូចតម្រងនោម គាត់ត្រូវការព្យាបាលដោយវិធី លាងឈាម (Hemodialysis) ឬដោយការប្តូរតម្រងនោមថ្មី (Kidney Transplantation) ។ មកទល់ទសវត្សឆ្នាំ 1970 គ្រូពេទ្យច្រើនពុំព្យាបាលអ្នកអ្នកជម្ងឺទឹកនោមផ្អែមដោយវិធីទាំងនេះ ឡើយ ពីព្រោះគេយល់ថា ការមានជម្ងឺទឹកនោមផ្អែមអាចធ្វើឲ្យវិធីព្យាបាលដោយការលាងឈាមឬផ្លាស់តម្រងនោមថ្មីពុំមានប្រសិទ្ធិភាព។ ប៉ុន្តែ ក្នុងពេលបច្ចុប្បន្ននេះ ដោយសារការព្យាបាលខាងជម្ងឺទឹកនោមផ្អែមមានប្រសិទ្ធភាព ហើយមានអ្នកជម្ងឺច្រើនអាចរស់នៅបានយូរ គ្រូពេទ្យពុំស្ទាក់ស្ទើរនឹងព្យាបាលអ្នកជម្ងឺខូចតម្រងនោមដោយវិធីទាំងនេះឡើយ។

សព្វថ្ងៃ លទ្ធផលនៃការព្យាបាលដោយប្រើវិធីលាងឈាមនិងផ្លាស់តម្រងនោមថ្មីទៅលើអ្នកជម្ងឺទឹកនោមផ្អែម មានលទ្ធផលល្អដូចគ្នានឹងការព្យាបាលទៅលើអ្នកជម្ងឺ ដទៃទៀតផងដែរ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ចំនួនអ្នកជម្ងឺទឹកនោមផ្អែមដែលស្លាប់បាត់បង់ជីវិត បន្ទាប់ពីការព្យាបាលដោយវិធីលាងឈាមនិងផ្លាស់តម្រងនោមថ្មី ច្រើនមានកំរិតខ្ពស់ដែរ។ នេះគឺមកពីអ្នកជម្ងឺនោះ មានអាការរោគផ្សេងៗដែលកើតមកពីជម្ងឺទឹកនោមផ្អែមមួយជាន់រួចទៅហើយ។

ក្នុងពេលបច្ចុប្បននេះ បញ្ហានៃការកើតជម្ងឺទឹកនោមផ្អែមនឹងជម្ងឺខូចតម្រងនោមបានត្រូវគេលើកយកមកពិភាក្សាយ៉ាងមមាញឹក។ អ្នកជំនាញការមានជំនឿថា មិនយូរប៉ុន្មាន អ្នកខូចតម្រងនោមចំនួនពាក់កណ្តាលអាចកើតមកពីជម្ងឺទឹកនោមផ្អែម។ ការពិនិត្យធ្វើតែស៍ឲ្យដឹង ថាតើនរណាមួយដែលអាចកើតជម្ងឺខូចតម្រងនោមនេះ អាចជាកត្តាជួយឲ្យអ្នកជំនាញការមានលទ្ធភាពនឹងចាត់វិធានការណ៍ការពារ ដូចជាវិធីការពារកុំឲ្យមានជម្ងឺទឹកនោមផ្អែម ដែលសិក្សាអំពីវិធីរក្សាជម្ងឺនេះនិងការស្កាត់ទប់កុំឲ្យមានជម្ងឺលើសឈាមផងដែរ។ ការរកឃើញនូវថ្នាំសំរាប់ជួយអ្នកជម្ងឺដែលទើបនឹងប្តូរតម្រងនោមថ្មី កុំឲ្យធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរទៅទៀត អាចជួយឲ្យវិធីផ្លាស់ប្តូរតម្រងនោម សំរាប់អ្នកជម្ងឺទឹកនោមផ្អែមមានជោគជ័យបាន។

នៅថ្ងៃអង្គារ៍ទី 24 ខែ តុលា ឆ្នាំ 2006 ខាងមុខនេះ គ្រឹស្ថានជាតិខាងជម្ងឺតម្រងនោម ហៅថា National Kidney Foundation ព្រមទាំងកម្មវិធីសុខភាពសហាគមខ្មែរ 2010 នៃមណ្ឌលសុខភាពសហាគមក្រុងឡូវែល នឹងរៀបចំធ្វើជាទិវាពិនិត្យជម្ងឺខូចតម្រងនោមមួយដោយឥតគិតថ្លៃមួយនៅមណ្ឌល Mercier Center អស័យដ្ឋាន លេខ 21 Market St. ក្នុងទីក្រុងឡូវែល។ ដូច្នេះ សូមអញ្ជើញអស់លោក-លោកស្រីទៅពិនិត្យឲ្យបានច្រើនកុករ។

ចំពោះពត៌មានបន្ថែមស្តីអំពីជម្ងឺខូចតម្រងនោម សូមមេត្តាអានវិបសៃរបស់ គ្រឹស្ថានជាតិខាងជម្ងឺតម្រងនោម ហៅថា National Kidney Foundation www.kidney.org ឬប្រសិនបើមានបំណងចង់ជ្រាបច្បាស់អំពីទិវាពិនិត្យជម្ងឺខូចតម្រងនោម នៅទីក្រុងឡូវែល សូមមេត្តាទូរស័ព្ទទៅ កម្មវិធីសុខភាពសហាគមខ្មែរ 2010 នៃមណ្ឌលសុខភាពសហាគមក្រុងឡូវែល ដែលមានលេខ (978) 746-7829។

*អត្ថបទនេះដកស្រង់និងបកប្រែពី "Kidney Diseases of Diabetes" ពីមន្ទីរក្សាឯកសារជាតិខាងពត៌មានស្តីអំពីតម្រងនោមនិងជម្ងឺជម្ងឺផ្លូវនោម (National Kidney and Urologic Diseases Information Clearinghouse) ដែលជាកម្មវិធីរបស់វិជ្ជាស្ថានជាតិខាងជម្ងឺ ទឹកនោមផ្អែម, រំលាយអាហារ, និង ជម្ងឺ តម្រងនោម (National Institute of Diabetes and Digestive and Kidney Disease) ដោយមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហាគមន៍ក្រុងឡូវែល។ http://kidney.niddk.nih.gov/kudiseases*